# សារាណីយធម៌

ព្រះមហាចន្ទសិរី ជាច់ សឿង៍

ទេសនាដាក់វិទ្យុប្រទេសកម្ពុជា

កាលពីថ្ងៃ៨រោច ខែចេត្រ ឆ្នាំជូតសំឫទ្ធិស័ក

ព.ស.២៤៩១ (២១-៤-៤៩)

ទស្សនាវដ្ដីកម្ពុជសុរិយា

ឆ្នាំទី២៥ លេខ៩ ខែកញ្ញា ព.ស.២៤៩៦ គ.ស.១៩៥៣

# សារាណីយធម៌

ព្រះមហាចន្ទសិរី ជាច់ ស៊ឿន

ទេសនាដាក់វិទ្យុប្រទេសកម្ពុជា

កាលពីថ្ងៃ៨រោច ខែចេត្រ ឆ្នាំជូតសំរឹទ្ធិស័ក

ព.ស.២៤៩១ (២១-៤-៤៩)

***

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

"សូមនមស្ការចំពោះព្រះភគវន្តមុនីអរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃដោយគោរព)"។

តអំពីនេះទៅ សូមសម្តែង សារាណីយធម៌ ផ្សាយតាមវិទ្យុឧគ្ឃោសនសព្ទ តាមសមគួរដល់កាលវេលា។

ពាក្យថា "សារាណីយធម៌" នេះ ប្រែថា "ធម៌ដែលបុគ្គលគប្បីរឭក" ចែកចេញជាមេមាតិកាមាន៦យ៉ាង គឺៈ

១–កាយកម្មប្រកបដោយមេត្តា,

២–វចីកម្មប្រកបដោយមេត្តា,

៣–មនោកម្មប្រកបដោយមេត្តា,

៤–ចែកលាភដែលបានមកដោយធម៌ដល់គ្នីគ្នា,

៥–រក្សាសីលឲ្យបរិសុទ្ធស្មើគ្នា,

៦–បញ្ញាយល់ឃើញត្រូវគ្នា។

សូមលើយយកបទមាតិកាមួយម្ដងៗ មកអធិប្បាយពង្រីកសេចក្ដីដូចតទៅនេះ ៖

**កាយកម្មប្រកបដោយមេត្តា** –មុននឹងអធិប្បាយបទមាតិកានេះ សូមដកយកពាក្យ “មេត្តា” មកប្រែនិងអធិប្បាយជាតួយ៉ាងខាងដើមសិន។

មេត្តា ប្រែថា “មេត្រី, សេចក្ដីស្និទ្ធ, ការរាប់អាន, សេចក្ដីស្រឡាញ់, ធម្មជាតិដែលមានក្នុងមិត្រឬប្រព្រឹត្តទៅដល់មិត្រ”។ បើសម្ដែងតាមលក្ខណៈ, កិច្ច, ផលនិងអាសន្នហេតុវិញ មេត្តានេះមានការប្រព្រឹត្តទៅដោយអាការជាប្រយោជន៍ ជាលក្ខណៈ (គ្រឿងកំណត់កត់សម្គាល់), មានការប្រមូលទុកនូវប្រយោជន៍ជាកិច្ច (ភ្នាក់ងារភារៈ), មានការកម្ចាត់បង់នូវគំនុំគុំក្ជួនជាផល, មានការឃើញនូវសភាពជាទីគាប់ចិត្តពេញប្រាថ្នានៃសត្វទាំងឡាយជាអាសន្នហេតុ។

កាយកម្មប្រកបដោយមេត្តានេះ មានអត្ថាធិប្បាយថា មនុស្សនិករគ្រប់ជាតិ-ភាសា ដែលឧប្បត្តិឡើងក្នុងភាជនលោកទាំងមូលនេះ ទោះរួមសញ្ជាតិ រួមភេទ រួមទីលំនៅភូមិឋានស្រុកទេសជាមួយគ្នាក៏ដោយ ផ្សេងគ្នាក៏ដោយ សុទ្ធតែមានការប្រស្រ័យជាប់ទាក់ទងរកគ្នាជាដរាប។ គ្មាននរណាមួយកើតមករស់នៅទោលតែឯកឯង ដោយគ្មានការប្រស្រ័យរកគ្នាទេ។ ឯគោលការណ៍ប្រស្រ័យគ្នា មានត្រឹមតែ ៣យ៉ាងគឺៈ ១-ខាងផ្លូវកាយ, ២-ខាងផ្លូវសម្តី, ៣-ខាងផ្លូវចិត្ត។

ចំពោះមាតិកានេះ, ខសំខាន់បំផុត ជនរួមសញ្ជាតិភាសា រួមលទ្ធិនិងវត្តប្រតិបត្តិដូចគ្នា ត្រូវធ្វើជាដាច់ខាត។ កិច្ចការទាំងពួងតាំងពីការងារតូចតាចបន្តិចបន្តួច មានការថែសម្អាតជួសជុលទីលំនៅជាដើមរហូតដល់ការងារធំៗ, កាលបើកើតឡើងក្នុងពួកក្រុមនីមួយៗ ហើយមិនត្រូវធ្វើកាយឲ្យរឹងគាំងឬមើលនឹងភ្នែក ចិត្តព្រងើយកន្តើយឥតរវីរវល់ទេ ត្រូវនាំគ្នាខ្នះខ្នែងយកចិត្តទុកដាក់ ចាប់នេះលើកនោះ ជ្រោមជ្រែងធ្វើកិច្ចការនោះៗ លុះត្រាតែបានសម្រេច។

ម្យ៉ាងទៀត ពួកជនដែលរួមសង្គមជាមួយគ្នា មានរោគាពាធបៀតបៀន ទោះធ្ងន់ក្តី ស្រាលក្តី មិនត្រូវដំងើច មើលបំណាំទេ ត្រូវ

នាំគ្នាឈឺឆ្អាល ចាត់ចែងទឹកក្ដៅទឹកត្រជាក់ រកថ្នាំសង្កូវមកបុកដុស លាបស្រឡាបគក់ច្របាច់រឹតរួតពួតសរសៃដៃជើង បោកគក់លាង សម្អៀកបំពាក់និងសេនាសនៈនៃអ្នកជម្ងឺឲ្យស្អាតបាតជាដើម។ ការបម្រើជម្ងឺនេះ គួរយកតម្រាប់ព្រះបរមគ្រូរបស់យើង កាលព្រះអង្គថែទាំជម្ងឺភិក្ខុមួយរូបឈ្មោះបូតិគត្តតិស្សៈ ដោយព្រះហស្តព្រះអង្គ ជាតួយ៉ាង។

មនុស្សណាដែលនៅក្នុងពួកក្រុមជាមួយគ្នា មិនរវីរវល់មិនអើពើធ្វើដៃជើងឲ្យគាំងដូចស្លាប់ ធ្ងន់ដូចថ្មភ្នំលើកកម្រើកមិនរួច ផាប់ស្ពូកដូចដង្កត់ឈើ ក្នុងពេលមានកិច្ចរវល់កើតឡើងក្នុងពួក គណៈរបស់ខ្លួន, មនុស្សនោះ នឹងទៅជាអ្នកខ្វះមិត្រ ខ្វះការរាប់អាន រស់នៅកំព្រាទោលតែឯង។ ទីបំផុត គ្មានហេតុអ្វីដទៃ ក្រៅពីការក្រៀមមុខដេកគងដៃលើថ្ងាសកើតទុក្ខ តូចចិត្តតឹងទ្រូង ថ្ងូរតែម្នាក់ឯង ក្នុងពេលមានទុក្ខធុរៈកើតឡើងចំពោះខ្លួននោះទេ។ ការយកចិត្តទុកដាក់ជួយជ្រោមជ្រែងដល់ធុរៈគ្នាដោយមេត្រីចិត្ត តែងជួបប្រទះនឹងគំនរសេចក្ដីសុខចម្រើន ដូចមានភាសិតសម្ដែងទុកថា **អត្ថម្ហិ ជាតម្ហិ សុខា សហាយា** “កាលបើមានកិច្ចរវល់កើតឡើង មិត្រសម្លាញ់ឬគ្នីគ្នា

ទាំងឡាយ តែងនាំសេចក្តីសុខមកឲ្យ"។

វចីកម្មប្រកបដោយមេត្តា –មានអធិប្បាយថា សម្តីសំដៅដែលត្រូវនិយាយទៅកាន់បុគ្គលដទៃ ក្នុងសង្គមជាមួយគ្នាម្តងៗ គួរប្រើវាចាល្អ ប្រកបដោយសេចក្តីពន្យល់អាងហេតុផល មានការប្រាប់ប្រងទាញគោលការណ៍ពិតមកលាតត្រដាងឲ្យឃើញ ដាស់តឿនចង្អុលប្រាប់គុណទោស, ល្អអាក្រក់, ត្រូវខុស, ហេតុមានប្រយោជន៍ឥតប្រយោជន៍ ក្នុងបច្ចុប្បន្ននិងបរលោកជាដើម។ ពេលនិយាយសោតទៀត គួរនិយាយឲ្យសមរម្យតាមគោលចារឹកលក្ខណៈរបស់វាចាល្អទាំង៥យ៉ាង គឺៈ

១-ពោលពាក្យតាមកាលគួរ សេចក្តីថាមុននឹងនិយាយគួរពិចារណាមើលថា ពេលនេះ គួរអាត្មាអញនិយាយបានឬមិនបាន, បើឃើញថាគួរនិយាយក៏និយាយ បើមិនគួរទេក៏ឈប់ស្ងៀម។

២-ពោលពាក្យសច្ចៈ សេចក្តីថា សម្តីណាមិនវេរុះ មិនសាដើម មិនកែប្រែជាថ្មីទៀត ជាសម្តីមិនមានពីរ ពោលទៀងទាត់ពិតមែន ហៅថាពាក្យសច្ចៈ។ សម្តីដែលយើងនិយាយក្នុងទីសន្និបាតម្តងៗ មិនមែនចេញផុតពីមាត់ភ្លាម ហើយសាត់បាត់ទៅតាមរលក

ធាតុអាកាសទេ ទៀងតែនឹងចូលទៅកាន់ត្រចៀកបុគ្គលដទៃជាប្រាកដ។ ហេតុនោះអ្នកនិយាយ ត្រូវស្វែងរកការពិតឲ្យឃើញ សឹមហាមាត់និយាយ។ បើហេតុផលមិនពិតទេ ស៊ូទ្រាំស្ងៀម បិទប្រអប់មាត់ឲ្យជិតល្អជាង។ ពាក្យសម្ដីពិតត្រង់ អាចធ្វើមនុស្សឲ្យមានតម្លៃបាន ទើបមានពាក្យបុរាណភាសិតថា "ស៊ូបង់ទ្រព្យកុំឲ្យបង់សម្ដី, មនុស្សគេយកសម្ដី ដំរីគេយកភ្លុក, ស្ងៀមជាជាងស្រដី, អណ្ដាតជាអាទិ៍កន្លង បានសុខទុក្ខផងពីព្រោះអណ្ដាត"។ អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម ប្រកបដោយវិចារណបញ្ញា ឈ្វេងយល់ឃើញគុណានិសង្សនៃពាក្យសច្ចៈ ទើបប្រកាសសេចក្ដីពិតថា ៖

សច្ចំ វេ អមតា វាចា  ឯស ធម្មោ សនន្តនោ

សច្ចេ អត្ថេ ច ធម្មេ ច  អាហុ សន្តោ បតិដ្ឋិតា។

"គួរឲ្យសរសើរពេក ពាក្យពិតជាពាក្យមិនចេះស្លាប់, ធម៌នេះជាប្រវេណីមានមកតាំងពីបុរាណ, សប្បុរសទាំងឡាយ បានតាំងនៅក្នុងហេតុនិងផលដ៏ពិតត្រង់"។

មួយយ៉ាងទៀត ពាក្យសច្ចៈនេះ អាចឲ្យផលប្រចក្សជាក់ស្ដែងក្នុងបច្ចុប្បន្នទាន់ភ្នែកឃើញ គឺអាចការពារជីវិតខ្លួននិងក្រុមគ្រួសារឲ្យ

ផុតអំពីមរណភាពបាន, តួយ៉ាងដូចអធិមុត្តកសាមណេរនិងមហាសុ-តសោមបណ្ឌិតជាដើម។ បានជាមានភាសិត ក្នុងកិន្នរវត្ថុ អដ្ឋកថាតក្ការិយជាតក ក្នុងតេរសនិបាត ប្រកាសទុកមកថា៖

តស្មា មរណតោ មោក្ខំ បត្ថយន្តេន ជន្តុនា
បហាយ អលិកំ សច្ចំ ភាសិតព្វំ សុធីមតា។

“ព្រោះហេតុនោះ សត្វដែលមានប្រាជ្ញាល្អ កាលប្រាថ្នាឲ្យផុតអំពីមរណៈ ត្រូវលះបង់ពាក្យឡេះឡោះចោល ហើយពោលតែពាក្យពិតចុះ”។

៣-ពោលពាក្យស្រទន់ផ្អែមល្ហែម គឺនិយាយពាក្យពីរោះល្អ នាំឲ្យអ្នកស្តាប់កើតសេចក្តីជ្រះថ្លាសោមនស្សបាន។

៤-ពោលពាក្យប្រកបដោយប្រយោជន៍ គឺពាក្យពោលពន្យល់ប្រាប់ហេតុផលនិងការខុសត្រូវក្នុងបច្ចុប្បន្ននិងបរលោក, ការនិយាយទូន្មាន ឲ្យចេះរៀបចំខ្លួនប្រាណមានរបៀបរៀបរយគ្រប់ឥរិ-យាបថទាំងបួន ស្លៀកដណ្តប់បិទបាំងរាងកាយនិងដាស់គំនិតឲ្យដឹងការខុសត្រូវជ្រៅរាក់, ការនិយាយពន្យល់ប្រាប់ប្រយោជន៍ខាងកសិ-កម្ម, ឲ្យខំព្យាយាមប្រឹងប្រែងស្វែងរកទ្រព្យសម្បត្តិ ដោយការភ្ជួររាស់

កាប់គាស់កកាយធរណី បណ្ដុះដាំស្រូវ, ពោត, សណ្ដែក, លូនិងដំ-
ណាំនានាជាបុព្វន្នជាតិនិងអបរន្នជាតិក្ដី ខាងពាណិជកម្ម ដូវជំនួញ
ជួញលលក់ទាំង២ពួកគឺ ជង្ឃពាណិជ (ឈ្មួញសម្ពាយ), សកដពា-
ណិជ (ឈ្មួញទូករទេះកប៉ាល់និងឈ្មួញធម្មតាតាមផ្ទះផ្សារ) ក្ដី ហៅថា
ពោលពាក្យប្រកបដោយប្រយោជន៍។ មួយយ៉ាងទៀត ការនិយាយ
សរសើរគុណសម្បត្តិវិទ្យាសាស្ដ្រដាស់គំនិតអ្នកស្ដាប់ឲ្យចូលចិត្តស្រ-
ឡាញ់ការសិក្សារៀនសូត្រដោយន័យថា នែកុមារកុមារីទាំងឡាយ !
វិទ្យាឬសាស្ដ្រក្នុងលោកនេះច្រើនណាស់ តែបើបំប្រួញឲ្យខ្លីមកមាន
ត្រឹមតែ៥យ៉ាងគឺ **នីតិវិជ្ជា** បានដល់វិជ្ជាខាងការសិក្សារៀនសូត្រ
អក្សរសាស្ដ្រ លេខនព្វន្ធ គុណហាជាដើម១, **យន្ដវិជ្ជា** បានដល់
វិជ្ជាខាងគ្រឿងចក្រយន្ត (គ្រឿងម៉ាស៊ីន) ទាំងអស់១, **វេជ្ជវិជ្ជា** បាន
ដល់វិជ្ជាពេទ្យហ្មចេះមន្ដអាគមឬពេទ្យផ្សំថ្នាំ១, **រដ្ឋវិជ្ជា** បានដល់វិជ្ជា
ខាងផ្លូវច្បាប់សម្រាប់ប្រទេស១, **យុទ្ធវិជ្ជា** បានដល់វិជ្ជាចម្បាំង១
បណ្ដាវិជ្ជាឬសាស្ដ្រទាំង៥យ៉ាងនេះ សុទ្ធតែមានប្រយោជន៍សម្រាប់
ខ្លួននិងប្រទេសជាតិទាំងអស់, វិជ្ជាមិនដែលអាក្រក់ទេ មានតែមនុស្ស
ទេតើទើបអាក្រក់, អ្នកត្រូវខំប្រឹងប្រែងសិក្សា ខាំមាត់អត់ធន់តស៊ូនឹង

សេចក្ដីទុក្ខលំបាកគ្រប់យ៉ាង ប្ដូរយកវិជ្ជាសម្បត្តិណាមួយឲ្យបាន ទាន់ខ្លួនអ្នកកំពុងតាំងនៅក្នុងយោព្វនវ័យដើម្បីនឹងកែខ្លួនអ្នកឲ្យជាមនុស្សម្នាក់ ឋិតនៅក្នុងឋានៈដ៏ខ្ពង់ខ្ពស់ ព្រមទាំងលើកស្ទួយប្រទេសជាតិមាតុភូមិអ្នកឲ្យមានតម្លៃ ឃ្លាតឆ្ងាយពីហីនភាពនិងទាសភាពឡើង ហេតុនេះ ចូរអ្នកកុំខ្ជិលកុំទម្រន់ទម្លាក់ក្រាញធ្វើអត្តភាពប្រហែលគ្នានឹងដង្កត់ឈើឬដុំថ្មឡើយ, អ្នកទាំងឡាយមិនធ្លាប់បានស្ដាប់ទេឬ ? ពាក្យសុភាសិតថាៈ

អបុត្តកំ ឃរំ សុញ្ញំ រដ្ឋំ សុញ្ញំ អរាជិកំ

អសិប្បស្ស មុខំ សុញ្ញំ សព្វសុញ្ញំ ទលិទ្ទកំ។

ផ្ទះដែលឥតកូនសូន្យស្ងប់ស្ងាត់

ដែនដែលឥតក្សត្រសូន្យអាជ្ញា

មាត់ឥតសិល្បសាស្ត្រសូន្យពាក្យចរចា

ខ្សត់ក្រកំព្រាសូន្យសព្វទាំងអស់។

ការទូន្មានពន្យល់ប៉ុណ្ណោះជាដើម ចាត់ថាវាចាប្រកបដោយប្រយោជន៍ផ្លូវបច្ចុប្បន្ន។

ចំណែកខាងវាចា ប្រកបដោយប្រយោជន៍ផ្លូវបរលោកវិញ

បានដល់ការនិយាយដាស់តឿន ឲ្យមានសទ្ធាជឿបុណ្យបាប, រក្សាសីល, លះលោភៈនិងមច្ឆរិយៈចេញ ហើយបរិច្ចាគទាន និងបញ្ញាសម្រាប់ពិចារណា ឲ្យដឹងហេតុផលសព្វគ្រប់ រហូតដល់ការពិចារណាអត្តភាពថា ជាគ្រោងកាយបិតនៅក្នុងកណ្តាប់ដៃសាមញ្ញលក្ខណធម៌ទាំង៣ គឺ ទុក្ខំ, អនិច្ចំ, អនត្តា ល្មមកើតធម្មសង្វេគចំពោះបញ្ចក្ខន្ធ ដោះខ្លួនគេចចេញចាកភពវាលវដ្តសង្សារដែលកំពុងឆេះសន្ធោសន្ធៅដោយភ្នក់ភ្លើងទាំង៣ គឺ រាគៈ ទោសៈ មោហៈ។

វាចាប្រាសចាកប្រយោជន៍ បើទុកជាបុគ្គលអង្គុយនិយាយប៉ប៉ោចដូចលាជផ្ទុះតាំងពីព្រលឹមទល់ព្រលប់ ពីព្រលប់ទល់ភ្លឺក៏ដោយ មិនអាចយកទៅប្រៀបធៀបនឹងវាចាជាប្រយោជន៍ សូម្បីមួយចំណិតបានឡើយ។ ព្រោះហេតុនោះ បានជាព្រះបរមគ្រូជាមហាអ្នកប្រាជ្ញទ្រង់ប្រកាសគាថា ទុកជាឧត្តមគតិថាៈ

សហស្សមបិ ចេ វាចា អនត្ថបទសញ្ហិតា
ឯកំ អត្ថបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ។

“បុគ្គលស្តាប់នូវបទណា ហើយស្ងប់រម្ងាប់បាន, បទនោះជាបទមានប្រយោជន៍ សូម្បីតែមួយ គង់ប្រសើរជាងវាចាមួយពាន់ម៉ាត់

ដែលមិនប្រកបដោយប្រយោជន៍”។

**៥-ពោលពាក្យដោយចិត្តមេត្តា** គឺនិយាយដោយសេចក្ដីអនុគ្រោះអាណិតអាសូរ ប្រាថ្នាឲ្យកើតប្រយោជន៍ពិតៗ មិនប្រាថ្នាកម្រៃអ្វី។ អ្នកពោលវាចាល្អទាំង៥យ៉ាងនេះសឹងជាប្រយោជន៍ខ្លួននិងអ្នកដទៃគ្រប់ៗខ។

មនោកម្មប្រកបដោយមេត្តា –មានអត្ថាធិប្បាយថាចិត្តដែលត្រិះរិះពិចារណា ស្រាវជ្រាវរាវរកមធ្យោបាយ ដោយសន្តិវិធីចំពោះករណីយកិច្ចប្រកបដោយហេតុផល ដើម្បីញ៉ាំងសន្តិសុខនិងថាវរៈប្រយោជន៍ឲ្យកើតមានឡើងក្នុងសង្គមនីមួយៗ ទាំងខំប្រឹងរិះរកកលឧបាយ រក្សាការពារសេចក្ដីសុខនិងប្រយោជន៍ដែលបានមកហើយឲ្យរឹងរឹតតែរឹងប៉ឹងឋិតថេរទៅទៀត ហៅថាមនោកម្មប្រកបដោយមេត្តា។ ការពិចារណាយល់កិច្ចកល តាំងចិត្តជាសប្បុរសរកគ្នាទៅវិញទៅមករវាងមនុស្សនិងមនុស្សជងគ្នាក្នុងគណៈជាមួយគ្នាបានចាត់ថាជាគុណសម្បត្តិមួយដ៏ប្រសើរបំផុត ព្រោះមានបុរាណភាសិតថា:

ក្រកិច្ចក្រកល ក្រដឹងក្រយល់ ក្រវៃឆ្លៃទាស់

ក្របានជាធំ លើគេទាំងអស់ ក្រចិត្តសប្បុរស នឹងមនុស្សជងគ្នា។

ក្រធំបំផុត គឺក្រទី៧ខាងចុង។

ចែកលាភដែលបានមកដោយធម៌ដល់គ្នីគ្នា –មានអត្ថាធិប្បាយថា លាភប្រកបដោយធម៌ ខាងបព្វជិត បានដល់ចតុប្បច្ច័យ កើតឡើងអាស្រ័យកម្លាំងស្មារបស់ខ្លួន ខំដើរស្វែងរកតាមច្រកល្ហកប្រាសចាកបាបធម៌៥និងអនេសនៈ២១។ ពុំនោះសោតកើតឡើងដោយអាស្រ័យទាយក ទាយិកា ជ្រះថ្លាក្នុងគុណសម្បត្តិនិងចរិយាសម្បត្តិខ្លួនហើយប្រគេនមក។ ខាងគ្រហស្ថ បានដល់លាភសក្ការៈកើតឡើងត្រឹមត្រូវតាមធម៌ប្រាសចាកបញ្ចវេរាជាដើម។ លាភបែបនេះបើបានមកហើយ មិនគួរហួងហែងទុកសម្ញុំបរិភោគប្រើប្រាស់តែឯងទេ ត្រូវចែកចាយគ្នីគ្នាបរិភោគប្រើប្រាស់តាមមានតាមបាន។ មនុស្សរួមសំវាសឬសង្គមជាមួយគ្នា បើបានលាភសក្ការៈមកហើយ លាក់លៀមទុកបរិភោគប្រើប្រាស់តែម្នាក់ឯង ភ្លេចសម្លឹងឃើញសេចក្ដីទុក្ខអ្នកដទៃ មិនខុសគ្នាអំពីបុរាណភាសិតថា "ចូលព្រៃសត្វសាហាវ រកអំពាវគ្នាមកជុំ ដល់បានស្កាទឹកឃ្មុំ ពួនសម្ញុំស៊ីម្នាក់

ឯង", ពុទ្ធភាសិតថា **សក្ការោ កាបុរិសំ ហន្តិ** "គ្រឿងសក្ការៈតែងសម្លាប់បុគ្គលអាក្រក់" ដូច្នេះ។

**រក្សាសីលឲ្យបរិសុទ្ធស្មើគ្នា** –មានអត្ថាធិប្បាយថា អ្នកដែលតាំងវិរតិចេតនាវៀរគ្រប់សិក្ខាបទ ដែលខ្លួនសមាទានហើយ រៀបចំកាយទ្វារ មនោទ្វារនិងវចីទ្វារ ឲ្យមានរបៀបរៀបរយហៅថា អ្នកមានសីល។ ការមិនចាប់កាន់គ្រឿងសស្ត្រាវុធ, ព្រនង់ដំបង ដោយហោចទៅសូម្បីបហរណវត្ថុដទៃៗទៀត ដើម្បីពិឃាដសត្វ ឈ្មោះថាជាគុណសម្បត្តិផ្នែកបាណាតិបាត។ ការមិនលួចកាត់របង ឬបើករបងច្រកល្ហក កាត់ទីតមានជញ្ជាំងផ្ទះ ពុះបំបែកតុទូ ឆក់ដណ្តើមយកទ្រព្យសម្បត្តិអ្នកដទៃជាដើម ឈ្មោះថាជាគុណសម្បត្តិផ្នែកអទិន្នាទាន។ ការមិនកន្លងប្រវេណីធម៌ គឺមិនលួចកូនប្រពន្ធអ្នកដទៃ ដោយអាការកំហែងប្រើអំណាចជាដើម ឈ្មោះថាជាគុណ-សម្បត្តិផ្នែកកាមេសុមិច្ឆាចារៈ។ ការមិននិយាយកុហកភូតភរ ឈ្មោះថាជាគុណសម្បត្តិផ្នែកមុសាវាទ។ ការមិនចាប់ពាល់ដបឬកែវ ដែលពេញដោយទឹកស្រវឹង មានសុរានិងមេរ័យជាដើម ឈ្មោះថាជាគុណ-សម្បត្តិផ្នែកសុរាមេរ័យ។

មនុស្សក្នុងក្រុមនីមួយៗ បើមានការវៀរបានដូចគ្នា ចំពោះសិក្ខាបទសម្រាប់ភេទរបស់ខ្លួនហើយ ឈ្មោះថាជាអ្នកមានសីលដូចគ្នា។

ចំពោះសមណភេទវិញ ក៏មានលំនាំដូចគ្នាដែរ។ អ្នកនៅក្នុងសង្គមជាមួយគ្នា មានសីលស្មើគ្នា រមែងបានសេចក្ដីសុខសេចក្ដីចម្រើនសព្វពេលវេលា។

បញ្ញាយល់ឃើញត្រូវគ្នា –មានអត្ថាធិប្បាយថា ទិដ្ឋិនេះជាតួបញ្ញា បានដល់ញាណម្យ៉ាងសម្រាប់ពិចារណារកហេតុផលសព្វគ្រប់។ ជនមានចំនួនច្រើន រួមសង្គមជាមួយគ្នាត្រូវប្រើគំនិតឲ្យស្រប គ្នា គឺមានការយល់ឃើញចំពោះប្រយោជន៍ក្នុងសង្គមជាមួយគ្នាតែម្យ៉ាង។ ដ្បិតការយល់ឃើញផ្ទុយគ្នាខុសឃ្លាងគ្នា មួយទៅឆ្វេងមួយទៅស្ដាំ ទុកថាជាទោសមួយយ៉ាងធំ អាចទម្លាយមិត្តសាមគ្គី ព្រមទាំងសន្តិសុខនិងប្រយោជន៍គ្រប់ស្ថានក្នុងសង្គមឲ្យរលាយបាន។

**ប្រយោជន៍របស់សារាណីយធម៌នោះមាន៦យ៉ាងគឺ**

១–ជាទីស្រឡាញ់ពេញចិត្តអ្នកដទៃ,

២–ជាទីគោរពរាប់អានអ្នកដទៃ,

៣–បានសេចក្ដីសង្គ្រោះអំពីសម្មាក់អ្នកដទៃ,

៤–មិនវិវាទទាស់ទែងខ្វែងគំនិតនឹងអ្នកណាមួយឡើយ,

៥–សាមគ្គីធម៌តែងកើតមានឡើង,

៦–មានការយល់ឃើញត្រូវគ្នា។

សម្ដែងធម៌ទេសនា អំពីសារាណីយធម៌ ល្មមសមគួរដល់កាលវេលាតែប៉ុណ្ណោះ។

ទីបំផុតនេះ សូមថ្វាយព្រះរាជកុសល ចំពោះព្រះករុណាជាម្ចាស់ជីវិត ព្រមទាំងអាណាប្រជារាស្ត្រ ក្នុងព្រះរាជាណាចក្រទាំងមូល សូមឲ្យបានប្រកបដោយសុខភាពនិងវឌ្ឍធម៌គ្រប់យ៉ាងកុំបីឃ្លាតឡើយ!

រតនត្តយតេជេន កម្ពោជរដ្ឋវាសិនោ
វុឌ្ឍិ វិរុឡ្ហិ បប្បោន្តុ សន្តិភាវញ្ច នាញ្ញថា។

ដោយតេជះនៃព្រះរតនត្រ័យ សូមឲ្យប្រជាជននៅក្នុងកម្ពុជរដ្ឋ ដល់នូវសេចក្ដីចម្រើនលូតលាស់និងសន្តិភាព កុំបីឃ្លាតក្លាយទៅជាបការៈដទៃឡើយ។

បរិយាយអំពីសារាណីយធម៌ ចប់តែប៉ុណ្ណោះ

## ធ្វើម្ដេចប្រទេសជាតិនឹងចម្រើន!

ប្រទេសជាតិនឹងចម្រើនរុងរឿង ដោយសារមានប្រជា-រាស្ត្រច្រើន ហើយប្រជារាស្ត្រនោះមានសាមគ្គីធម៌ មិនមែនមកពីអ្នកមានសម្បត្តិទ្រព្យបីបួននាក់នោះទេ។

យ. អ.

***

Khmer K21
News & Media Website

ស្រាវជ្រាវដោយៈ ជាច់ សុតឹម